ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបឯកអគ្គរាជទូតថៃប្រចាំកម្ពុជា ដែលទើបតែងតាំងថ្មី



នៅរសៀលថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួប ឯកឧត្តម **Nuttavudh Photisaro** ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា ដែលទើបតែងតាំងថ្មី ដើម្បីសំដែងការគួរសម និងពិភាក្សាការងារ នៅទីស្តីការក្រសួង ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងចាត់ទុកបេសកកម្មញកាទូត របស់ឯកឧត្តម **Nuttavudh Photisaro** នៅកម្ពុជា នឹងពង្រឹងពង្រីកបានថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អប្រសើរ រវាងកម្ពុជា–ថៃ ដែលជាប្រទេសភូមិផងរបងជាមួយ ។

ឯកឧត្តម **Nuttavudh Photisaro** ឯកអគ្គរាជទូតថៃប្រចាំកម្ពុជា ដែលទើបតែងតាំងថ្មី បានសម្តែងនូវទឹកចិត្តរីករាយចំពោះការមកបំពេញបេសកកម្មការទូតនៅកម្ពុជា និងបានវាយតម្លៃ និងកោតសរសើរ ចំពោះភាពរីកចម្រើនលើគ្រប់វិស័យរបស់កម្ពុជា ក្នុងរយៈពេល២០ ឆ្នាំចុងក្រោយនេះ ។ ការរីកចម្រើនដ៏ឆាប់រហ័សនេះ ឯកឧត្តម ឯកអគ្គរាជទូតថៃ បានសំដៅទៅដល់ការដឹកនាំដ៏វាងវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ** ហ៊ុន សែន ដែលធ្វើឱ្យប្រទេសមានសុខសន្តិភាព និងការអភិវឌ្ឍន៍រហូតដល់បច្ចុប្បន្ននេះ ។ ទាក់ទង និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច ឯកឧត្តម ឯកអគ្គរាជទូតថៃ បានមើលឃើញភាពរីកចម្រើននៃកំណើនសេដ្ឋកិច្ចតាមព្រំដែន តាមរយៈការដោះដូរទំនិញយ៉ាងមមាញឹករវាងប្រជាពលរដ្ឋ និងអាជីវករ នៃប្រទេសទាំងពីរ ក្នុងនោះនៅរាជធានីភ្នំពេញក៏មានវត្តមានក្រុមហ៊ុន និងភោជនីយ៍ដ្ឋានថៃ ជាច្រើនគួរកត់សំគាល់ផងដែរ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានលើកឡើងពីកត្តាអំណោយផលរបស់កម្ពុជា ។ ក្នុងនោះកត្តាអំណោយផលដ៏សំខាន់សម្រាប់កម្ពុជា–ថៃនោះ គឺ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានអំពាវនាវឱ្យអ្នកវិនិយោគថៃមកបណ្តាក់ទុននៅកម្ពុជាឱ្យបានច្រើនថែមទៀត ជាពិសេសការបង្កើតរោងចក្រក្នុងតំបន់សេដ្ឋកិច្ច ពិសេស ដែលមានតាមព្រំដែនរវាងប្រទេសទាំងពីរ ។ ផលប្រយោជន៍ គឺៈថៃផ្ទេរបច្ចេកវិទ្យាទំនើបរបស់ខ្លួនធ្វើការផលិតនាំចេញទៅទីផ្សារដែលខ្លួនមានស្រាប់ ដោយប្រើប្រាស់ កលំាំងពលកម្ម និងប្រភពដើមទំនិញរបស់កម្ពុជា ដែលអាចនាំចេញទៅទីផ្សារក្រៅប្រទេសជាច្រើន ដោយមិនជាប់ពន្ធ និងមិនជាប់កូតា ពីព្រោះកម្ពុជា ទទួលភាពអនុគ្រោះពាណិជ្ជកម្មពីបណ្តាប្រទេសទាំងនោះ នូវមុខទំនិញរាប់ពាន់មុខ ។

ទាក់ទងនិងការវាយតម្លៃទទួលស្គាល់ (Accreditation) ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបញ្ជាក់ថាៈ កាលពី ខែកុម្ភៈ កន្លងទៅ ក្រសួងឧស្សាហកម្មនិងសិប្បកម្មកម្ពុជា និងក្រសួងឧស្សាហកម្មថៃ បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ស្តីពីកិច្ចសប្រតិបត្តិការលើការងារវាយតម្លៃទទួលស្គាល់ ។ ទាក់ទងបញ្ហានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្នើឱ្យឯកឧត្តមឯកអគ្គរាជទូតថៃ ធ្វើការសម្របសម្រួល ដើម្បីឱ្យកម្ពុជាមានលទ្ធភាពចុះហត្ថលេខា លើអនុស្សារណៈយោគយល់គ្នាជាមួយស្ថាប័នបីទៀតដ៏ទៃទៀតរបស់ថៃ គឺក្រសួងកសិកម្ម ក្រសួងវិទ្យាសាស្រ្ត និងក្រសួងសុខភាពសាធារណៈ ពីព្រោះការងារវាយតម្លៃទទួលស្គាល់របស់ថៃស្ថិតនៅក្រោមស្ថាប័នទាំងបីខាងលើផងដែរ។ ការសម្រេចបានការងារនេះ នឹងធ្វើឱ្យការងារវាយតម្លៃទទួលស្គាល់កម្ពុជា ឈានចូលទៅក្នុងគម្រោងសហប្រតិបត្តិការទ្វេរភាគីកម្ពុជា–ថៃ ជាពិសេស នឹងរួមចំណែកជួយជម្រុញការធ្វើពាណិជ្ជកម្មនាំចេញ–នាំចូល ដោយកាត់បន្ថយរបាំងបច្ចេកទេស និងកាត់បន្ថយនូវការចំណាយលើការធ្វើធុរៈកិច្ច ព្រមទាំងជួយសម្រួលដល់អ្នកប្រើប្រាស់ ក្នុងនិងក្រៅប្រទេសឱ្យទទួលបាននូវផលិតផល រឺទំនិញមានគុណភាព សុវត្ថិភាព និងផាសុខភាព ក្នុងដំណាក់កាលដែលសហគមន៍សេដ្ឋកិច្ចអាស៊ាននឹងលេចចេញជារូបរៀង នៅចុងឆ្នាំ២០១៥ ខាងមុខនេះ ។

